KHMER

BreastScreen
NEW SOUTH WALES

ការថតឆ្លុះពិនិត្យមើលដោះដោយឥតគិតថ្លៃ

# ការពិនិត្យរកឃើញ បានទាន់ពេល គឺជាការការពារ ដ៏ប្រសើរបំផុតរបស់អ្នក

(Early detection is your best protection)

*សំរាប់ស្ត្រីដែលមានអាយុចាប់ពី៥០ឆ្នាំ ទៅ៦៩ឆ្នាំ រៀងរាល់ពីរឆ្នាំម្តង*

## ហេតុអ្វីបានជាការថតឆ្លុះពិនិត្យមើលដោះជាគំនិតល្អ?

ពេលវេលាដ៏ល្អបំផុតសំរាប់ព្យាបាលជម្ងឺមហារីកដោះ គឺធ្វើនៅពេលជម្ងឺនេះទើបតែមានរូបរាងនៅតូចនូវឡើយ។ វាប្រហែលជារាប់ឆ្នាំទៅមុខ មុននឹងអ្នក ឬវេជ្ជបណ្ឌិតរបស់អ្នកសម្គាល់ឃើញថាកើតមានបញ្ហា។ ការថតឆ្លុះពិនិត្យមើលដោះ អាចរកឃើញបញ្ហាបានទាន់ពេល។ ការថតឆ្លុះពិនិត្យមើលដោះ មិនមែនឃាត់ឃាំងអ្នកឲ្យរួចផុតពីការកើតមានជម្ងឺមហារីកដោះនោះទេ ក៏ប៉ុន្តែវាអាចផ្តល់ជូនអ្នកនូវឱកាសដ៏ប្រសើរជាង ដើម្បីទទួលការព្យាបាលឲ្យបានជោគជ័យ។

## តើនាងខ្ញុំស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ឬ?

នៅក្នុងពេលបច្ចុប្បន្ននេះនៅក្នុងរដ្ឋញូវសៅវែល មានស្ត្រី១នាក់នៅក្នុងចំណោមស្ត្រី១១នាក់ ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់នៃការកើតមានជម្ងឺមហារីកដោះ ក្នុងមួយឆាកជីវិតរបស់គេ។ កត្តាគ្រោះថ្នាក់ដ៏ធំជាងគេបំផុតគឺដោយសារតែមានភាពជាស្ត្រីភេទ ហើយមានអាយុលើសពី៥០ឆ្នាំ។

## តើគេនឹងធ្វើអ្វីខ្លះនៅពេលនាងខ្ញុំទៅកន្លែង BreastScreen NSW?

អ្នកទទួលភ្ញៀវរបស់យើងនឹងស្វាគមន៍អ្នក ស្នើសុំឲ្យអ្នកបំពេញហ្វ័មមួយបន្ទាប់មកគេនាំអ្នកទៅកាន់បន្ទប់ប្តូរសម្លៀកបំពាក់ ដែលនៅទី នោះអ្នកត្រូវដោះអាវចុះមកដល់ត្រឹមចង្កេះ។ អ្នកបច្ចេកទេសដោយវិទ្យុកម្មរស្មីអិក្ស នឹងនាំអ្នកទៅឯម៉ាស៊ីនថតឆ្លុះពិនិត្យមើលដោះ។ គេនឹងយកចិត្តទុកដាក់លៃលកថតដោះម្តងម្ខាងៗ ពីលើម៉ាស៊ីនថតឆ្លុះពិនិត្យមើលដោះ។ នឹងមានវេជ្ជបណ្ឌិតឯកទេសពិសេសពីរ រូបពិនិត្យមើលការថតឆ្លុះពិនិត្យមើលដោះនោះ។

## តើមានអារម្មណ៍យ៉ាងណាដែរនៅពេលថតឆ្លុះពិនិត្យមើលដោះ?

ពេលថតឆ្លុះពិនិត្យមើលដោះ ស្ត្រីខ្លះមានអារម្មណ៍មិនស្រួលបន្តិចដោយព្រោះការថតឆ្លុះនោះត្រូវការសង្កត់ដោះ ដ្បិតអីការសង្កត់គឺជា ការសំខាន់ណាស់ដើម្បីថតរូបឲ្យបានឃើញច្បាស់។ ការសង្កត់ដោះគ្រាន់តែប្រើពេលតែ២ ទៅ៣វិនាទីប៉ុណ្ណោះ។ ស្ត្រីភាគច្រើនពោលថាផលប្រយោជន៍ គឺល្អប្រសើរជាងអារម្មណ៍មិនស្រួលតែមួយភ្លែតនោះ។

## តើការថតឆ្លុះពិនិត្យមើលដោះមានសុវត្ថិភាពយ៉ាងណាដែរ?

វិទ្យុសកម្មប្រើសំរាប់នៅពេលថតឆ្លុះពិនិត្យមើលដោះ គឺមានកំរិតទាបបំផុត។ ការសិក្សាស្រាវជ្រាវបានបង្ហាញឲ្យឃើញថា ផលប្រយោជន៍ ពីការថតឆ្លុះពិនិត្យមើលដោះ គឺមានភាពប្រសើរច្រើនជាងសភាពគ្រោះថ្នាក់ដែលអាចកើតមានពីវិទ្យុសកម្ម។ ផលប្រយោជន៍ ដែលបានទទួលសំរាប់ខាងសុខភាពនោះគឺថា ប្រសិនបើគេរកឃើញជម្ងឺមហារីកដោះបានទាន់ពេល នោះអ្នកនឹងមានឱកាសរស់រានមានជីវិតខ្ពស់ជាង ដោយព្រោះតែមានវិធីព្យាបាលច្រើនជាងសំរាប់ជ្រើសរើស។

## តើការថតឆ្លុះពិនិត្យមើលដោះផ្តល់ជូនដោយឥតគិតថ្លៃឬ?

BreastScreen NSW ជាកិច្ចបំរើថតឆ្លុះពិនិត្យមើលដោះ ដែលត្រូវបានឧបត្ថម្ភដោយរដ្ឋាភិបាលរដ្ឋញូវសោវែល ដើម្បីផ្តល់កិច្ចបំរើថតដោះរៀងរាល់ពីរឆ្នាំម្តង សំរាប់ស្ត្រីដែលមានអាយុពី៥០ឆ្នាំ ទៅ៦៩ឆ្នាំ។ BreastScreen NSW គឺជាផ្នែកនៃកម្មវិធីសុខភាពជាតិមួយផ្តល់កិច្ចបំរើថតឆ្លុះពិនិត្យមើលដោះដែលមានគុណភាពខ្ពស់។

ចំពោះស្ត្រីដែលមានអាយុពី៤០ឆ្នាំ ទៅ៤៩ឆ្នាំនិង៧០ឆ្នាំឡើងក៏អាចស្នើសុំការថតឆ្លុះពិនិត្យមើលដោះនៅ BreastScreen NSW បានដែរ។

ការថតឆ្លុះពិនិត្យមើលដោះនៅ BreastScreen NSW មិនមានសំរាប់ស្ត្រីដែលមានអាយុនៅក្រោម៤០ឆ្នាំទេ។

## ចុះប្រសិនបើនាងខ្ញុំមានបញ្ហាដោះ?

ប្រសិនបើអ្នកមានបញ្ហាដោះដូចជាកើតមានដុំ ឈឺ ឬហៀរទឹកនៅតាមចុងដោះ អ្នកគួរតែទៅជួបវេជ្ជបណ្ឌិតព្យាបាលជម្ងឺទូទៅរបស់អ្នក មុននឹងអ្នករៀបចំការណាត់ពេលជួបជាមួយ BreastScreen NSW។

## តើនាងខ្ញុំអាចធ្វើអ្វីផ្សេងទៀតបាន?

ការថតឆ្លុះពិនិត្យមើលដោះ អាចតាមដានរកឃើញជម្ងឺមហារីកដោះភាគច្រើន ក៏ប៉ុន្តែមិនមែនទាំងអស់ទេ។ ដូច្នេះសូមអ្នក:

- មកថតឆ្លុះពិនិត្យមើលដោះនៅកន្លែង BreastScreen NSW រៀងរាល់ពីរឆ្នាំម្តង ប្រសិនបើអ្នកមានអាយុចាប់ពី៥០ឆ្នាំ ទៅ៦៩ឆ្នាំ។
- ឲ្យវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាយិកាផ្នែកសុខភាពស្ត្រី ពិនិត្យមើលដោះរបស់អ្នកមួយឆ្នាំម្តង រៀងរាល់ឆ្នាំ។
- ទៅជួបវេជ្ជបណ្ឌិតភ្លាម ប្រសិនបើអ្នកកត់សម្គាល់ឃើញភាពប្រែប្រួលទាំងឡាយនៅក្នុងដោះរបស់អ្នក ដូចជាកើតមានដុំ ឈឺ ឬហៀរទឹកនៅតាមចុងដោះ សូម្បីតែការថតដោះបង្ហាញលទ្ធផលជាធម្មតាក៏ដោយ។

## តើនាងខ្ញុំអាចរៀបចំការណាត់ពេលជួបដោយបែបណា?

សូមទូរស័ព្ទទៅលេខ 13 20 50 ដើម្បីរៀបចំការណាត់ពេលជួបដោយឥតគិតថ្លៃនៅកន្លែង BreastScreen NSW ដែលនៅជិតលោកអ្នកជាងគេ។ គឺគ្មានពេលណាដែលល្អប្រសើរ ជាងពេលឥឡូវនេះទេ។ យើងនឹងទន្ទឹងរង់ចាំទទួលទូរស័ព្ទអំពីអ្នក។

**មានមណ្ឌលថតឆ្លុះពិនិត្យមើលដោះជាង២០០កន្លែង ពេញទូទាំងរដ្ឋញូវសោវែល។**

ចំពោះការណាត់ពេលជួប និងចម្ងល់ទាំងឡាយសូមទូរស័ព្ទលេខ:

**13 20 50**

(អស់ថ្លៃទូរស័ព្ទដូចក្នុងតំបន់)

ដើម្បីទទួលយកជំនួយនៃអ្នកបកប្រែភាសា សូមទូរស័ព្ទលេខ:

**13 14 50**

ចំពោះពត៌មានបន្ថែមទៀតអំពី BreastScreen NSW សូមបើកមើលនៅត្រង់គេហទំព័រ:

**www.bsnsw.org.au**